00657120

E50/3/1/1

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Mar-2011, 15:40
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំឲ្យដោះលែងជាបន្ទាន់

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Motoo NOGUCHI
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម A. KLONOWIECKA- MILART
ចៅក្រម ស៊ិន រិទ្ធ
ចៅក្រម C. N. JAYASINGHE
ចៅក្រម យ៉ា ណារិន

**ចម្លងជូន:**
**ជនជាប់ចោទ**
**ខៀវ សំផន**

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សរ ស្វាន
លោក Jacques VERGÈS
លោក Phillipe GRECIANO

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**

ពេជ អង្គ

Elisabeth SIMONNEAU FORT

## I. សេចក្តីផ្តើម

១- នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេត (សចស) បានចេញដីកាដំណោះស្រាយរបស់ខ្លួន ដោយធ្វើការចោទប្រកាន់ ខៀវ សំផន ("ជនជាប់ចោទ") ចំពោះអំពើប្រល័យពូជសាសន៍ឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងអំពើរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ នៅក្នុងដីកាដំណោះស្រាយ សចស បានបង្គាប់ឱ្យបន្តឃុំខ្លួនជនជាប់ចោទរហូតដល់ពេលគាត់ត្រូវបាននាំខ្លួនមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[1]។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះ(អបជ)បានចេញសេចក្តីសម្រេចរបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទប្រឆាំងនឹងដីកាដំណោះស្រាយ ដោយច្រានចោលបណ្តឹងឧទ្ធរណ៍នេះថា មិនអាចទទួលយកបាន និងបង្គាប់ឱ្យបន្តឃុំខ្លួនគាត់ជាបន្តទៀត[2]។ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ អបជ បានផ្តល់សំអាងហេតុអំពីសេចក្តីសម្រេចរបស់ខ្លួននេះ ដែលនៅក្នុងនោះសេចក្តីសម្រេចបានអនុម័តលើទឡ្ហីករណ៍នានាដែល សចស បានពឹងផ្អែកដើម្បីធ្វើជាយុត្តិកម្មក្នុងការបន្តការឃុំខ្លួនជនជាប់ចោទ និងបានរកឃើញថា ពុំមានការផ្លាស់ប្តូរក្នុងកាលៈទេសៈដែលពាក់ព័ន្ធទេ[3]។

២- នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ ជនជាប់ចោទ បានដាក់សំណើសុំដោះលែងជាបន្ទាន់របស់ខ្លួន អនុលោមតាមអនុវិធាន៨២(៣)។ គាត់បានអះអាងនៅក្នុងសំណើសុំនេះថា អនុវិធាន៦៨(៣) (ដូចបានពង្រឹងបន្ថែមនៅក្នុងមាត្រា២៤៩ និង៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) តម្រូវឱ្យនាំខ្លួនគាត់មកចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេលបួនខែ នៃថ្ងៃចេញដីកាដំណោះស្រាយនិងថា ដោយសារកាលបរិច្ឆេទកំណត់

---

[1] ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០, D427, កថាខ័ណ្ឌទី ១៦២៤ ។

[2] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៣ មករា ២០១១, D427/4/14 ។

[3] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ២១ មករា ២០១១, D427/4/15, កថាខ័ណ្ឌទី២៩ ។

នេះមិនត្រូវបានបំពេញ គាត់ត្រូវតែបានដោះលែងដោយស្វ័យប្រវត្តិ[4]។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការមួយដើម្បីស្តាប់អំណះអំណាងផ្ទាល់មាត់លើសំណើសុំនេះ។ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ អង្គជំនុំជម្រះបានចេញ *សេចក្តីសម្រេចរបស់ខ្លួនលើសំណើសុំដោះលែងជាបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ* ,("សេចក្តីសម្រេចដែលកំពុងតវ៉ានេះ")[5]។ ក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ានេះ អង្គជំនុំជម្រះបានច្រានចោលសំណើសុំរបស់ជនជាប់ចោទ ដោយសម្រេចថាៈ អនុវិធាន ៦៨(៣) ផ្តល់ពេលវេលាសម្រាប់ការបន្តឃុំខ្លួនចំនួនបួនខែបន្ថែមដែលអាចនឹងត្រូវបានបង្គាប់ដោយ អបជ, ធ្វើការកត់សំគាល់ថា ការឃុំខ្លួនជនជាប់ចោទក្នុងអឡុងពេលនៃសវនាការ បន្តដោយស្វ័យប្រវត្តិ តាមអនុវិធាន៨២(១) និងការរកឃើញបន្ថែមទៀតថា ការបន្តការឃុំខ្លួនជនជាប់ចោទ គឺជាការត្រឹមត្រូវក្រោមលក្ខខណ្ឌនានាដែលមានចែងក្នុងអនុវិធាន៦៣(៣)(ក)និង៦៣(៣)(ខ)(iii)[6]។ជនជាប់ចោទបានដាក់បណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសេចក្តីសម្រេចដែលកំពុងតវ៉ានេះ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១[7] ។

៣- នៅក្នុងបណ្តឹងសាទុក្ខនេះ ជនជាប់ចោទអះអាងថា អង្គជំនុំជម្រះសាលាដំបូងៈ បានប្រព្រឹត្តកំហុសឆ្គងផ្នែកច្បាប់ ក្នុងការបកស្រាយរបស់ខ្លួនលើអនុវិធាន៦៨(៣); បានប្រព្រឹត្តកំហុសឆ្គងផ្នែកច្បាប់ទាក់ទិននឹងការផ្តល់សំអាងហេតុតាមអនុវិធាន៦៣(៣)(ខ)(iii) និងបានរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌របស់ខ្លួន តាមរយៈការខកខានមិនបានផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីត្រៀមការការពារខ្លួនគាត់ រួមទាំងតាមរយៈការខកខានមិនបានពិចារណាទៅលើសេចក្តីសន្និដ្ឋានរបស់គាត់នៅលើ

---

[4] សំណើសុំដោះលែង អនុលោមតាមអនុវិធាន៨២(៣) នៃវិធានផ្ទៃក្នុង, ២៥ មករា ២០១១, E18 ។

[5] សេចក្តីសម្រេចលើសំណើសុំឱ្យដោះលែងជាបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ, ថ្ងៃទី១៦ កុម្ភៈ ២០១១, E50 ("សេចក្តីសម្រេចដែលកំពុងតវ៉ា") ។

[6] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង, កថាខ័ណ្ឌទី៤០ ។

[7] បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំឱ្យដោះលែងជាបន្ទាន់, ២១ មីនា ២០១១, E50/3, ("បណ្តឹងសាទុក្ខ") ។

បញ្ហានៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងសាទុក្ខនេះ គួរតែបានច្រានចោលដោយសារមូលហេតុដូចតទៅ៖ i) អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានយ៉ាងត្រឹមត្រូវថា អនុវិធាន៦៨(៣)អនុញ្ញាតឱ្យមានចិរវេលាបួនខែ ចំនួនពីរដងខុសគ្នានៃការឃុំខ្លួននៅក្រោយការចេញដីកាដំណោះស្រាយ; ii) អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយ៉ាងត្រឹមត្រូវថា ការឃុំខ្លួន ជនជាប់ចោទបន្តដោយស្វ័យប្រវត្តិស្របតាមអនុវិធាន៨២(១) និងiii) ទោះបីអង្គជំនុំជម្រះសាលាដំបូងភាន់ច្រឡំទាក់ទិននឹងលក្ខខណ្ឌនានាដែលមានចែងក្រោមអនុវិធាន៦៣(៣)(ខ)(iii)ក៏ដោយ ក៏ការបន្តការឃុំខ្លួនជាប់ចោទ គឺជាការត្រឹមត្រូវ ហើយអង្គជំនុំជម្រះតុលាការកំពូល មានអំណាចដាក់សំអាងហេតុរបស់ខ្លួន ជំនួសសំអាងហេតុទាំងឡាយដែលបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូង។

## II. បទដ្ឋាននៃការត្រួតពិនិត្យ និងអំណាចរបស់អង្គជំនុំជម្រះតុលាការកំពូល ដើម្បីដាក់ជំនួសសំអាងហេតុ

៤- វិធាន១០៤ នៃវិធានផ្ទៃក្នុង បង្កើតនូវការសាកល្បងដែលមានមុខពីរសម្រាប់បណ្តឹងសាទុក្ខជាបន្ទាន់ប្រឆាំងនឹងសេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូង។ អនុលោមតាមវិធាននេះ ដើមបណ្តឹងសាទុក្ខត្រូវបង្ហាញឱ្យឃើញពី: ១) កំហុសឆ្គងដែលអាចឱ្យគេយល់ដឹងបាន នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង និង ២) ថាកំហុសឆ្គងនោះបានបង្កឱ្យខូចផលប្រយោជន៍របស់ដើមបណ្តឹងសាទុក្ខ[8]។ ទាក់ទិននឹងមុខព្រួញទីមួយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា ដោយសារអវត្តមាននៃការណែនាំក្នុងវិធាន និងក្រមនីតិវិធីព្រហ្មទណ្ឌ អង្គជំនុំជម្រះតុលាការកំពូល គួរអនុម័តតាមការសាកល្បងរបស់តុលាការ ICTY ស្តីពីវិសាលភាពនៃការត្រួតពិនិត្យ ដោយការសាកល្បងនេះត្រូវបានអនុវត្តតាមដោយ អបជ ដូចខាងក្រោម៖

[8] ក្រោមអនុវិធាន១០៤(១), បណ្តឹងសាទុក្ខភ្លាមៗអាចធ្វើទៅបានដោយផ្អែកលើ "មូលដ្ឋាននៃការភាន់ច្រឡំ ដែលស្តែងចេញពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍ដល់ដើមបណ្តឹងសាទុក្ខ" ។

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

"ដើម្បីអាចតវ៉ានឹងសេចក្តីសម្រេចឆន្ទានុសិទ្ធិមួយ ម្ចាស់បណ្តឹងសាទុក្ខត្រូវបង្ហាញថា "អង្គជំនុំជម្រះសាលាដំបូងសម្រេចខុសដោយខ្លួនឯង លើគោលការណ៍ដែលត្រូវអនុវត្ត ឬច្បាប់ដែលពាក់ព័ន្ធនឹងការអនុវត្តឆន្ទានុសិទ្ធនេះ" ឬត្រូវបង្ហាញថា អង្គជំនុំជម្រះសាលាដំបូង "[បានដាក់]ទម្ងន់ទៅលើការពិចារណាអង្គហេតុមិនពាក់ពន្ធ័,.....ខកខានមិនបានដាក់ទម្ងន់ ឬដាក់ទម្ងន់មិនបានគ្រប់គ្រាន់លើការពិចារណាដល់អង្គហេតុពាក់ព័ន្ធ ឬ...មានការភាន់ច្រឡំអង្គហេតុ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន" ឬសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងមាន"ភាពមិនសមហេតុផលទាល់តែសោះ ឬភាពអយុត្តិធម៌យ៉ាងច្បាស់ ដែលអង្គជំនុំជម្រះតុលាការកំពូលអាចទាញការសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង ប្រាកដជាបានខកខានក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនអោយបានត្រឹមត្រូវ"។ នៅក្នុងការអនុវត្ត ប្រភេទនៃកត្តាទាំងនេះ បង្កើតអោយមានវិធានសាមញ្ញដូចតទៅ៖ ការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង នឹងត្រូវបដិសេធចោលប្រសិនបើសេចក្តីសម្រេចត្រូវបានតវ៉ា (១) ផ្អែកលើការបកស្រាយមិនត្រឹមត្រូវនៃច្បាប់ជាធរមាន; (២) ផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវទាល់តែសោះទៅលើអង្គហេតុ ឬ (៣) អយុត្តិធម៌ ឬមិនសមហេតុផលដែលនាំអោយមានការរំលោភ បំពានឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង"[9]។

៥- នៅក្នុងបណ្តឹងឧទ្ធរណ៍ទាក់ទិននឹងការឃុំខ្លួន បើសិនសំអាងហេតុដែលបានផ្តល់ដោយអង្គជំនុំជម្រះសាលាដំបូង ត្រូវបានរកឃើញថា គ្មានភាពគ្រប់គ្រាន់នៃ *ភស្តុតាងមួយក្រឡេកផ្អែក* នោះត្រូវបើកចំហរ សម្រាប់

---

[9] សាលដីកាលើបណ្តឹងសាទុក្ខបន្ទាន់បង្គំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការចាត់តាំងមេធាវីការពារក្តី, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ១ វិច្ឆិកា ២០០៤, កថាខ័ណ្ឌទី១០ (សេចក្តីយោងត្រូវបានដកចេញ); ដែលបានអនុវត្តតាមនៅក្នុងរឿងក្តីបច្ចុប្បន្ន នៅក្នុង សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម, ១២ វិច្ឆិកា ២០០៩, D164/3/6, ទំព័រទី៩-១១ ។

អង្គជំនុំជម្រះតុលាការកំពូលពិចារណាចំពោះមូលដ្ឋានជាថ្មីសម្រាប់ការឃុំខ្លួន។ នៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ សចស នៅលើបញ្ហានៃការឃុំខ្លួនជនត្រូវចោទ [នៅពេលនោះ] អបជ បានអនុវត្តការវិភាគផ្ទាល់របស់ខ្លួនធៀបនឹងលក្ខណៈវិនិច្ឆ័យដែលមាននៅក្នុងអនុវិធាន៦៣(៣) តាមរយៈការគិតគូទៅលើសេចក្តីសន្និដ្ឋានរបស់គូភាគី និងភស្តុតាងនៅក្នុងសំណុំរឿងនៅថ្ងៃសវនាការ[10]។

៦- វានៅតែស្ថិតក្រោមឆន្ទានុសិទ្ធិរបស់អង្គជំនុំតុលាការកំពូល ដើម្បីតម្កល់ ឬកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងខណៈពេលដែលមានការដាក់សំអាងហេតុផ្សេងៗរបស់ខ្លួន ជំនួសសំអាងហេតុដែលបានផ្តល់ក្នុងសេចក្តីសម្រេច[11]។ អបជ បានប្រើយុទ្ធវិធីដូចនេះនៅក្នុងសេចក្តីសម្រេចមួយចំនួនលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនៃការឃុំខ្លួន[12]និងលើបណ្តឹងឧទ្ធរណ៍ដទៃទៀតប្រឆាំងនឹងសេចក្តីសម្រេចអំពីឆន្ទានុសិទ្ធិ ពេលដែល សចស បានខកខានក្នុងការផ្តល់សំអាងហេតុឱ្យបានគ្រប់គ្រាន់[13]។ ស្រដៀងគ្នានេះដែរ *ក្នុងករណី* Popovic នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY មិនបានផ្តល់សំអាងហេតុឱ្យបានគ្រប់គ្រាន់សម្រាប់សេចក្តីសម្រេចស្តីពីការដោះលែងជាបណ្តោះអាសន្ននោះ

---

[10] សូមអាន ជាឧទាហរណ៍: សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ៣០ មេសា ២០១០, C26/9/12, កថាខ័ណ្ឌទី២៥ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន នួន ជា, ២០ មីនា ២០០៨, C11/54, កថាខ័ណ្ឌទី៤២ ។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច", ៣ ធ្នូ ២០០៧, C5/45, កថាខ័ណ្ឌទី២៧ និងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ, ៩ កក្កដា ២០០៨, C20/I/26, កថាខ័ណ្ឌទី១៨ ។

[11] អនុវិធាន១០៤(១) ផ្តល់ឱ្យអង្គជំនុំជម្រះតុលាការកំពូលនូវឆន្ទានុសិទ្ធិ "ដើម្បីពិនិត្យលើភស្តុតាង និងស្វែងរកភស្តុតាងថ្មី" ខណៈដែលអនុវិធាន១០៤(២) ផ្តល់អំណាចអង្គជំនុំជម្រះ ដើម្បីកែប្រែសេចក្តីសម្រេចដែលបាននឹងកំពុងប្តឹងសាទុក្ខទាំងស្រុង ឬមួយផ្នែក។

[12] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ, ៩ កក្កដា ២០០៨, C20/I/26។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន នួន ជា, ២០ មីនា ២០០៨, C11/54 និងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កាំង ហ្កេកអ៊ាវ *ហៅ* "ឌុច", ៣ ធ្នូ ២០០៧, C5/45។

[13] សាលដីកាលើបណ្តឹងឧទ្ធរណ៍ និងសេចក្តីសន្និដ្ឋានបន្ថែមជំទាស់នឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើរបស់ នួន ជា សុំឱ្យស្តាប់ចម្លើយសាក្សីមួយចំនួន (D318, D319, D320, D336, D338, D339 & D340), ២០ កញ្ញា ២០១០, D375/1/8, កថាខ័ណ្ឌទី១០២។

អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានពិចារណាទៅលើភស្តុតាងនានាចំពោះបញ្ហានេះ ហើយបានផ្តល់សំអាងហេតុរបស់ខ្លួនផ្ទាល់[14] ។

## III. អង្គជំនុំជម្រះសាលាដំបូងបានធ្វើការសន្និដ្ឋានយ៉ាងត្រឹមត្រូវថា វិធាន៦៨ ផ្តល់ថិរវេលាបួនខែចំនួនពីរដងខុសគ្នា

៧- ជនជាប់ចោទសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូង បានដឹកនាំបង្ហាញខ្លួនឯងដោយខុសចំពោះគោលការណ៍ច្បាប់ជាធរមាននៅក្រោម អនុវិធាន៦៨(៣) និងបានខកខានផងដែរក្នុងការផ្តល់សំអាងហេតុនានាក្នុងការឆ្លើយតបទៅនឹងអំណះអំណាងរបស់គាត់ដែលថា បទប្បញ្ញត្តិនោះអនុញ្ញាតឱ្យតែថិរវេលាបួនខែនៃការឃុំខ្លួនតែម្តងប៉ុណ្ណោះ។ ផ្ទុយទៅនឹងសេចក្តីសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានពិចារណានិងបានទាត់ចោលអំណះអំណាងរបស់គាត់ ហើយនៅក្នុងការសម្រេចដូច្នេះ អង្គជំនុំជម្រះក៏បានធ្វើការចង្អុលបង្ហាញអំពីពាក្យពេជច៏ច្បាស់លាស់នៃអនុវិធាន៦៨(៣) នេះ[15]។

៨- សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានឈានដល់ការសន្និដ្ឋានផ្លូវច្បាប់ត្រឹមត្រូវចំពោះអនុភាពនៃអនុវិធាន៦៨(៣)។ អំណះអំណាងរបស់ជនជាប់ចោទធ្វើមិនដឹងមិនឮចំពោះភាសាដ៏សាមញ្ញនៃបទប្បញ្ញត្តិនេះ ៖

---

[14] តុលាការ ICTY, *រដ្ឋអាជ្ញា ទល់នឹង Popovic*, សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធការដោះលែងបណ្តោះអាសន្ន Ljubomir Borovcanin, ១ មីនា ២០០៧, កថាខ័ណ្ឌទី១៣-២០ ។

[15] កថាខ័ណ្ឌទី៤៣ នៃសេចក្តីសម្រេចដែលកំពុងតវ៉ា ។

"ក្នុងករណីណាក៏ដោយ សេចក្តីសម្រេចរក្សាទុកជនជាប់ចោទនៅក្នុងឃុំជាបណ្តោះអាសន្ន ឬរក្សាលក្ខខណ្ឌនៃការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់សហចៅក្រមស៊ើបអង្កេត **ឬអង្គបុរេជំនុំជម្រះ** ត្រូវអស់អនុភាពក្នុងរយៈពេល៤(បួន)ខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ" (សង្កត់ន័យត្រង់អក្សរដិតធំ និងគូសបន្ទាត់ពីក្រោម)។

៩- បើសិនទទួលយកសេចក្តីសន្និដ្ឋានរបស់ជនជាប់ចោទ ពាក្យថា "**ឬអង្គបុរេជំនុំជម្រះ**" នឹងត្រូវលែងប្រើការ[16] ហើយអនុភាពរបស់វាគឺច្បាស់ណាស់ថា: សេចក្តីសម្រេចរបស់ អបជ ដើម្បីរក្សាទុកជនជាប់ចោទនៅក្នុងឃុំជាបណ្តោះអាសន្ន ត្រូវអស់អនុភាពក្នុងរយៈពេល៤(បួន)ខែក្រោយ លើកលែងតែជនជាប់ចោទត្រូវបាននាំខ្លួនទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលនោះ"។ អាស្រ័យហេតុនេះ វិធានដែលចែងអំពីលទ្ធភាពនៃរយៈពេលឃុំខ្លួនបួនខែចំនួនពីរដង: ដែលលើកទីមួយអាចត្រូវបានបង្គាប់ដោយ សចស នៅក្នុងដីកាដំណោះស្រាយ និងលើកទីពីរដែលអាចត្រូវបានបង្គាប់ដោយ អបជ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ។

១០- ជនជាប់ចោទតវ៉ាថា អង្គជំនុំជម្រះសាលាដំបូងបានធ្វើមិនដឹងមិនឮចំពោះអ្វីដែលជា "គោលជំហររបស់សហព្រះរាជអាជ្ញា ជាដរាបរៀងមក" - ដែលថា មានតែរយៈពេលបួនខែតែម្តងប៉ុណ្ណោះដែលនៅជាធរមានក្រោមវិធាន៦៨(៣)[17]។ សហព្រះរាជអាជ្ញាមិនបានប្រកាន់យកគោលជំហរដូច្នេះ នៅក្នុងការដាក់ឯកសារដូចដែលជនជាប់ចោទបានលើកយោងនោះឡើយ។ សេចក្តីសន្និដ្ឋានទាក់ទងនឹងអំណះអំណាងរបស់ នួន ជា ដែល

---

[16] សហព្រះរាជអាជ្ញាកត់សំគាល់ថា ក្នុងការដកស្រង់បទប្បញ្ញត្តិនេះ (ត្រង់កថាខ័ណ្ឌទី១៣ នៃបណ្តឹងសាទុក្ខ) ជនជាប់ចោទលុបចោលពាក្យដូចបានបញ្ជាក់ពីខាងលើ ។

[17] បណ្តឹងសាទុក្ខ, កថាខ័ណ្ឌទី១០ ។

ថា ការឃុំខ្លួននៅចំពោះមុខ អ.វ.ត.ក ត្រូវបានកម្រិតត្រឹមតែរយៈពេលសរុបបីឆ្នាំ។ នៅក្នុងការបង្ហាញពីវិវុទ្ធនិទស្សន៍នៃអំណះអំណាងនេះ សហព្រះរាជអាជ្ញាបានធ្វើការចង្អុលបង្ហាញចំពោះការពិតនៃអនុវិធាន ៦៨(៣)នេះថា វាអនុញ្ញាតឱ្យមានរយៈពេលនៃការបន្តឃុំខ្លួនចំនួនបួន៤ខែ *ដោយសហចៅក្រមស៊ើបអង្កេត* លើសពីរយៈពេលកំណត់បីឆ្នាំដែលអនុវត្តបានចំពោះកិច្ចស៊ើបសួរ។ វិធានមិនបាននិយាយទាក់ទិននឹងការបន្តការឃុំខ្លួនដោយ អបជ ទេ។ សហព្រះរាជអាជ្ញា កត់សំគាល់ផងដែរថា នួន ជា បានទទួលយកនៅក្នុងសំណើសុំរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា អង្គបុរេជំនុំជម្រះមានអំណាចដើម្បីបង្គាប់ឱ្យបន្តឃុំខ្លួនលើរូបគាត់[18]។

## IV. ការឃុំខ្លួនជនជាប់ចោទ បានបន្តតាមអនុវិធាន ៨២.១

១១. ដោយសារថាការឃុំខ្លួនជនជាប់ចោទត្រូវបាន អបជ ធ្វើការពន្យារដែលប្រកបទៅដោយសុពលភាព ហើយនិងជនចាប់ចោទត្រូវបាននាំទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈពេលបួនខែនៃសេចក្តីសម្រេចនោះ ការឃុំខ្លួនរបស់គាត់គឺត្រូវបន្តដោយស្វ័យប្រវត្តិ ដោយអនុលោម តាមអនុវិធាន ៨២.១។

១២. អនុវិធាន ៨២.១ និង ៨២.២ ចែងថា៖

១. ជនជាប់ចោទត្រូវមានសេរីភាពរហូតដល់ពេលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង លើកលែងតែមានការបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុងនេះ។ ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួននៅពេលចូលខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

[18] សំណើសុំដោះលែង នួន ជា ជាបន្ទាន់, ១៨ មករា ២០១១, E19, កថាខ័ណ្ឌទី១២-១៣ ។ សំណើបន្ទាន់ដើម្បីសុំដោះលែងអ្នកស្រី អៀង ធីរិទ្ធ ដោយឥតបង្អង់, ២១ មករា ២០១១, E21, កថាខ័ណ្ឌទី១១-១២ ។

ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដដែលរហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបានសម្រេចសេចក្តី លើកលែងតែករណីដែលមានចែងក្នុងអនុវិធាន ២ ខាងក្រោម។

២. គ្រប់ពេលនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះអាចបង្គាប់ឱ្យដោះលែងជនជាប់ចោទ ឬដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងករណីចាំបាច់ ឬបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទបានស្របតាមវិធានផ្ទៃក្នុងនេះ។ អង្គជំនុំជម្រះសាលាដំបូងត្រូវសម្រេចអំពីបញ្ហានេះ បន្ទាប់ពីបានស្តាប់ជនជាប់ចោទ មេធាវីជនជាប់ចោទ និងសហព្រះរាជអាជ្ញា។

១៣. បទប្បញ្ញត្តិនេះបានប្តូរយ៉ាងមានប្រសិទ្ធភាពនូវការសន្មតទាក់ទងទៅនឹងការឃុំខ្លួន ពីពេលដែលអង្គជំនុំជម្រះសាលាដំបូង បានចាប់ដំណើរការលើករណីរឿង៖ ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរជនត្រូវចោទនៅមានសេរីភាពជាងដែល លើកលែងតែមានការចេញដីកាបង្គាប់ឱ្យឃុំខ្លួន[19]។ ទោះជាយ៉ាងដូច្នេះក៏ដោយ បើជនជាប់ចោទស្ថិតនៅក្នុងការឃុំខ្លួននៅពេលដែលមកបង្ហាញខ្លួន លើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង គាត់ត្រូវស្ថិតនៅក្នុងការឃុំខ្លួនជាបន្តទៀតរហូតដល់ និងលើកលែងតែមានដីកាបង្គាប់ឱ្យដោះលែង។ បទប្បញ្ញត្តិក្រោយនេះគឺត្រូវគ្នាទៅនឹងវិធាននានាដែលនៅជាធរមាននៅចំពោះមុខតុលាការ *ពិសេស (ad hoc)* អន្តរជាតិ[20]។

១៤. អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តយ៉ាងត្រឹមត្រូវនូវវិធាននានា ដោយការសន្និដ្ឋានថា ត្រូវឃុំខ្លួនជន

---

[19] អនុវិធាន ៦៣.៣ ចែងថា ការឃុំខ្លួនបណ្តោះអាសន្នអាចត្រូវបានបង្គាប់តែកាលណាលក្ខខណ្ឌនានាដែលបានចែងនៅក្នុងបទប្បញ្ញត្តិនោះ ត្រូវបានបំពេញប៉ុណ្ណោះ ។

[20] វិធាន ៦៤ និង ៦៥ នៃវិធានស្តីពីភស្តុតាង និងនីតិវិធីនៃតុលាការ ICTY, ICTR និង តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន។

ជាប់ចោទជាបន្តទៀត ដោយអនុលោមតាមអនុវិធាន ៨២.១ លើកលែងតែក្នុងលទ្ធភាពនៃការដោះលែងមួយតាមអនុវិធាន ៨២.២[21]។ ជនជាប់ចោទបានធ្វើសំណើសុំដោះលែងជាបន្ទាន់ដោយមានមូលដ្ឋាននៅលើអំណះអំណាងដែលថា ការឃុំខ្លួនគាត់គឺកន្លងផុតហួសហើយ។ ដោយសារតែអង្គជំនុំជម្រះនេះបានបដិសេធអំណះអំណាងនោះ ការឃុំខ្លួនជនជាប់ចោទត្រូវធ្វើបន្តទៀតជាស្វ័យប្រវត្តិ។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ដល់ភាគីនានានូវកាលានុវត្តភាពមួយឱ្យធ្វើសារណាស្តីពីលក្ខខណ្ឌទាំងឡាយនៅក្នុងអនុវិធាន ៦៣.៣ ដោយស្វ័គ្រចិត្ត *(sua sponte)* ក៏ដោយ ក៏វាមិនថិតនៅក្រោមកាតព្វកិច្ចណាមួយដើម្បីធ្វើដូច្នោះឡើយ។ អាស្រ័យហេតុដូច្នេះ មិនថាការពិចារណាលើកត្តានានានៅក្នុងអនុវិធាន៦៣.៣ របស់អង្គជំនុំជម្រះនេះ វាយ៉ាងណានោះឡើយ ជនជាប់ចោទត្រូវបានឃុំខ្លួនដោយសុពលភាពជាបន្តទៀត។

## V. ការពិចារណារបស់អង្គជំនុំជម្រះលើកត្តានានានៃអនុវិធាន ៦៣.៣ មិនបានធ្វើឲ្យសេចក្តីសម្រេចរបស់ខ្លួនអស់សុពលភាពទេ

១៥. នៅក្នុងការពិចារណាលើលក្ខខណ្ឌដ៏សំខាន់នានានៃការឃុំខ្លួនក្នុងអនុវិធាន ៦៣.៣ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា៖ ទី១) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនជាប់ចោទរូបនោះធ្លាប់បានប្រព្រឹត្តបទល្មើសនានា ដែលត្រូវបានចោទប្រកាន់លើរូបគាត់ (អនុវិធាន ៦៣.៣.ក)[22], និងទី២) ការឃុំខ្លួនគឺជាការចាំបាច់ ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទក្នុងអំឡុងពេលសវនាការ (អនុវិធាន ៦៣.៣.ខ(៣)[23]។ ជនជាប់ចោទបានជំទាស់តវ៉ាតែទៅលើការរកឃើញទីពីរ

---

[21] សូមមើល ផ្នែកបញ្ញត្តិត្រង់ទំព័រទី១៥ នៃសេចក្តីសម្រេចដែលកំពុងតវ៉ា ។

[22] អនុវិធាន ៦៣.៣.ក ។ សូមមើល កថាខណ្ឌទី ៣៨ នៃសេចក្តីសម្រេចដែលកំពុងតវ៉ា ។

[23] អនុវិធាន ៦៣.៣.ខ(៣) ។ សូមមើល កថាខណ្ឌទី ៤០ នៃសេចក្តីសម្រេចដែលកំពុងតវ៉ា ។

ប៉ុណ្ណោះ ដោយបានលើកសំអាងថា អង្គជំនុំជម្រះនេះ បានបង្គាប់ដោយមានការភាន់ច្រឡំខ្លួនឯង អំពីគោលការណ៍ច្បាប់ជាធរមាននានា។ ដោយឡែក គាត់បានចង្អុលបង្ហាញពីការពឹងផ្អែករបស់អង្គជំនុំជម្រះនេះ ទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់តែឯកឯង ដើម្បីធ្វើយុត្តិកម្មលើការរកឃើញមួយដែលថា ការឃុំខ្លួន គឺជាការចាំបាច់ដើម្បីធានាអំពីវត្តមានរបស់គាត់នៅពេលសវនាការ[24]។

១៦. សហព្រះរាជអាជ្ញា ព្រមទទួលថា មូលហេតុនានាដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ គឺមិនគ្រប់គ្រាន់ដើម្បីឲ្យត្រូវទៅតាមពិសោធន៍នៅក្នុងអនុវិធាន៦៣.៣.ខ(៣)ទេ។ ដូចដែលប្រភពច្បាប់នានាដែលជនជាប់ចោទបានលើកឡើង បានបញ្ជាក់ថា អង្គហេតុពិតដែលគាត់ត្រូវបានបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះ មិនបានធ្វើយុត្តិកម្មលើការរកឃើញមួយ ដែលថា ការឃុំខ្លួនគឺជាការចាំបាច់ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងអំឡុងពេលនៃដំណើរការនីតិវិធី[25]។ ទោះជាយ៉ាងនេះក៏ដោយការណ៍នេះមិនបានធ្វើឲ្យសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះអស់សុពលភាពទេ ហើយវាក៏មិនប៉ះពាល់ដល់សុពលភាពនៃការបន្តការឃុំខ្លួនដែរ។

១៧. អង្គជំនុំជម្រះសាលាដំបូង បានយល់ពីសារៈសំខាន់នៃការផ្តល់នូវមូលហេតុនានាដ៏គ្រប់គ្រាន់និង ដោយឡែកនៅក្នុងរឿងនេះបានយោងទៅដល់បញ្ហានៃការឃុំខ្លួន[26]។ បទប្បញ្ញត្តិរបស់ខ្លួន អំពីមូលហេតុដែលនៅមានកម្រិតទាក់ទងទៅនឹងទឡ្ហីករណ៍នៅក្នុងអនុវិធាន៦៣.៣.ខ(៣) គួរតែត្រូវបានពិនិត្យសារឡើងវិញពីបរិបទនៃអង្គហេតុទាំងឡាយដូចតទៅនេះ៖

---

[24] បណ្តឹងសារទុក្ខ, កថាខណ្ឌទី ១៩-២២ ។

[25] ត្រង់កន្លែងដដែល (Ibid.) ។

[26] សេចក្តីសម្រេចដែលកំពុងតវ៉ា, កថាខណ្ឌទី ៣៣ កន្លែងដែលអង្គជំនុំជម្រះ "បានទទួលស្គាល់ពីសារៈសំខាន់ដោយឡែកនៃការ ពិចារណាហេតុផលទាក់ទងនឹង [សេចក្តីសម្រេចឃុំខ្លួន]" ។

ក. ជនជាប់ចោទ មិនបានធ្វើសំណើសុំដោះលែងដោយឈរលើមូលដ្ឋាននៃអនុវិធាន៦៣.៣ ទេ ហើយគាត់ក៏មិនបានជំទាស់តវ៉ានៅក្នុងសំណើរបស់គាត់ថា វាមានការផ្លាស់ប្តូរកាលៈទេសៈណាមួយដែរ ចាប់តាំងពីមានសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះក្នុងការពន្យារការឃុំខ្លួនគាត់មក។ សំណើសុំដោះលែងរបស់គាត់មានមូលដ្ឋាននៅលើតែការដាក់ជូនផ្សេងៗពាក់ព័ន្ធទៅនឹងអានុភាពនៃអនុវិធាន៦៨.៣ ប៉ុណ្ណោះ។

ខ. នៅក្នុងការសម្រេចលើសំណើនេះ អង្គជំនុំជម្រះនេះមិនបានអនុញ្ញាតឱ្យមានការដាក់សារណាជាលាយលក្ខអក្សរនៅលើទឡ្ហីករណ៍នានាក្នុងអនុវិធាន៦៣.៣ទេ ក៏ប៉ុន្តែ ផ្ទុយទៅវិញបានផ្តល់ដល់ភាគីនានានូវកាលានុវត្តភាពមួយក្នុងការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ស្តីពីបញ្ហានេះនៅពេលសវនាការទៅវិញ។

គ. នៅក្នុងសេចក្តីសម្រេចដែលកំពុងតវ៉ានោះ អង្គជំនុំជម្រះនេះ បានកត់សម្គាល់ថាមូលដ្ឋានដ៏ត្រឹមត្រូវសម្រាប់ការឃុំខ្លួនតាមអនុវិធាន៨២.១ ដែលមិនតម្រូវឱ្យមានការពិចារណាលើកត្តានានាក្នុងអនុវិធាន ៦៣.៣ ទេ។

១៨. ដោយឡែក អង្គជំនុំជម្រះនេះបានថ្លែងថា បើភាគីនានាមានបំណងធ្វើសំណើសុំដោះលែងណាមួយនៅពេលអនាគត អ្នកទាំងនោះមិនត្រូវបានតម្រូវឱ្យបង្ហាញពីការផ្លាស់ប្តូរកាលៈទេសៈណាមួយទេ។ អាស្រ័យហេតុដូច្នេះ វាបានបន្សល់ទុកដោយមិនបានប៉ះពាល់អ្វីដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការធ្វើសំណើសុំដោះលែងមួយ ដែលមានមូលដ្ឋាននៅលើលក្ខណៈវិនិច្ឆ័យនៅក្នុងអនុវិធាន៦៣.៣ ហើយបើ

ដូច្នេះ គឺបានធានាថាគ្មានភាពលំអៀងដាក់ទៅខាងជនជាប់ចោទពីការពិចារណារបស់ខ្លួនលើលក្ខណៈវិនិច្ឆ័យទាំងនោះនៅពេលសវនាការ ទេ ។

## VI. ក្នុងព្រឹត្តិការណ៍ណាក៏ដោយ ធាតុផ្សំតម្រូវសំខាន់ៗសម្រាប់ឃុំខ្លួនជនជាប់ចោទក្នុងអនុវិធាន ៦៣.៣ ត្រូវបានបំពេញ

១៩. ដូចដែលបានបញ្ជាក់នៅក្នុងផ្នែក II វាគឺបិតនៅលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការដឹកនាំធ្វើការពិនិត្យសារជាថ្មីឡើងវិញនូវអង្គហេតុនានា ហើយនិង ឬមួយក៏គាំទ្រ ឬមួយធ្វើវិសោធនកម្មលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយរួមទាំងការបញ្ចូលនូវការពិចារណារកហេតុផលរបស់ខ្លួនផ្ទាល់ផង។

២០. អនុវិធាន ៦៣.៣ ចែងថា៖

សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖

ក.មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើនដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ខ. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី៖

(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

(២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

(៤) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្ដាប់ធ្នាប់សាធារណៈ។

២១. លក្ខណៈវិនិច្ឆ័យនៅក្នុងអនុវិធាន ៦៣.៣.ក គឺជាលក្ខខណ្ឌ*ចាំបាច់ខានមិនបាន (sine qua non)* ។ បើវាត្រូវបានបង្ហាញថា វាគ្មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើនដែលត្រូវបានចោទប្រកាន់លើរូបគាត់ទេ នោះការឃុំខ្លួនមិនអាចត្រូវបានបង្គាប់បានឡើយ ហើយពុំចាំបាច់មានតម្រូវការឱ្យធ្វើការពិចារណាលើលក្ខខណ្ឌនានាក្នុងអនុវិធាន ៦៣.៣.ខ ទេ ។ ដូចដែលបានកត់សម្គាល់នៅក្នុងផ្នែក V ខាងលើ ជនជាប់ចោទមិនបានជំទាស់តវ៉ាលើការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាលក្ខខណ្ឌនៅក្នុង ៦៣.៣.ក ត្រូវបានបំពេញរួចហើយៗ ការចេញដីកាដំណោះស្រាយដោយ សចស បង្ហាញថាលក្ខខណ្ឌនោះត្រូវបានបំពេញយ៉ាងច្បាស់លាស់។ អាស្រ័យហេតុដូច្នេះ សហព្រះរាជអាជ្ញា នឹងផ្ដោតទៅលើលក្ខខណ្ឌនានានៅក្នុងអនុវិធាន ៦៣.៣.ខ ។

២២. ការឃុំខ្លួនបណ្ដោះអាសន្នលើជនជាប់ចោទ ត្រូវបានបង្គាប់ពីដំបូងដោយ សចស នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២00៧[27]។ ការពន្យារការឃុំខ្លួនលើកទីពីរ និងលើកចុងក្រោយ សំរាប់រយៈពេល១២ខែក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ត្រូវបានបង្គាប់នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២00៩ ដោយមានមូលដ្ឋានលើលក្ខខណ្ឌនានានៅក្នុងអនុវិធាន ៦៣.៣.ខ(៤) និង (៥) ត្រូវបានបំពេញរួចហើយ[28]។ អបជ បានគាំទ្រដល់សេចក្ដីសម្រេចនេះនៅក្នុងបណ្ដឹងឧទ្ធរណ៍[29]។ នៅក្នុងដីកាដំណោះស្រាយ ជាការបន្ថែមទៅលើទឡ្ហីករណ៍ទាំងនេះ សចស បានរកឃើញថា ការបន្តឃុំខ្លួនជនត្រូវចោទក៏ត្រូវបានធ្វើយុត្តិកម្មផងដែរដោយទឡ្ហីករណ៍ទាំងឡាយដែលមាននៅក្នុងអនុវិធាន ៦៣.៣.ខ(១), (២) និង (៣)[30]។ ទោះបីជាជនជាប់ចោទបានប្ដឹងឧទ្ធរណ៍លើដីកាដំណោះស្រាយក៏ដោយ ក៏គាត់មិនបានជំទាស់តវ៉ានឹងសេចក្ដីសម្រេចនេះដែរ[31] ហើយនៅខែមករា ឆ្នាំ២០១១ អបជ បានអនុម័តលើទឡ្ហីករណ៍ដូចគ្នានៅពេលដែលធ្វើការពន្យារការឃុំខ្លួនជនជាប់ចោទ[32]។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងសេចក្ដីសម្រេចដែលកំពុងតវ៉ា អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា មានតែអនុវិធាន ៦៣.៣.ខ(៣) ប៉ុណ្ណោះដែលត្រូវបានបំពេញ[33]។

---

27 ដីកាបង្គាប់ឃុំខ្លួនបណ្ដោះអាសន្ន, ថ្ងៃទី១៩ វិច្ឆិកា ២00៧, C26 ។

28 ដីកាសម្រេចអំពីការបន្តថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន, ថ្ងៃទី១៨ វិច្ឆិកា ២00៩, C26/8 ។

29 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន, ថ្ងៃទី៣០ មេសា ២០១០, C26/9/12 ។

30 ដីកាដំណោះស្រាយ, ថ្ងៃទី១៦ កញ្ញា ២០១០, D427, កថាខណ្ឌទី ១៦២៤ ។

31 បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី១០ វិច្ឆិកា ២០១០, D427/4/3 ។

32 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, ថ្ងៃទី២១ មករា ២០១១, D427/4/15, កថាខណ្ឌ ២៩។

33 សេចក្ដីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ, ថ្ងៃទី១៦ កុម្ភៈ ២០១១, E50, ត្រង់ កថាខណ្ឌ ទី ៤០ ។

២៣. ខណៈដែលធ្វើការកត់សម្គាល់សេចក្តីសម្រេចទាំងនេះ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា ការបន្តឃុំខ្លួនជនជាប់ចោទត្រូវបានធ្វើយុត្តិកម្មតាមអនុវិធាន៦៣.៣.ខ(៤) និង(៥) ហើយសូមធ្វើការលើកឡើងនូវលក្ខខណ្ឌទាំងឡាយនេះវិញម្តង។

## ក. ហានិភ័យចំពោះសន្តិសុខជនជាប់ចោទ

២៤. ជនជាប់ចោទ គឺជាអតីតប្រធានរដ្ឋ និងជាបុគ្គលដ៏ល្បីឈ្មោះមួយរូបដែលធ្លាប់បានឋិតនៅក្រោមអំពើហិង្សាជាសាធារណៈនានា ដែលជាលទ្ធផលនៃអតីតតួនាទីរបស់គាត់ក្នុងកម្ពុជាប្រជាធិបតេយ្យ និងក្នុងគណៈបក្សកុម្មុយនិស្តកម្ពុជា។ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៩១ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចមួយទៅកាន់ទីក្រុងភ្នំពេញ គាត់ត្រូវបានគេវាយប្រហារលើរូបរាងកាយ ហើយស្ទើរតែត្រូវបានពួកអ្នកតវ៉ាប្រឆាំងមួយក្រុមធ្វើប្រជាទណ្ឌ[34]។ ក្នុងឆ្នាំ២០០០ គាត់បានតម្រូវឱ្យមានការធានាសុវត្ថិភាពរបស់គាត់ជាមុនសិន ដើម្បីថ្លែងនៅក្នុងវេទិកាសាធារណៈមួយ[35]។

២៥. ព្រឹត្តិការណ៍ថ្មីៗបំផុតតទៅនេះ បង្ហាញថា សន្តិសុខរបស់ជនជាប់ចោទនៅមានហានិភ័យជាបន្តទៅទៀត ហើយថា ការដោះលែងអាចនឹងធ្វើឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់រូបគាត់៖

ក. អត្ថបទមួយចុះផ្សាយនៅក្នុងកាសែត the *New York Times* កាលពីថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៨ បានរាយការណ៍ថា ពាក់ព័ន្ធទៅនឹងពួកអតីតមេដឹកនាំខ្មែរក្រហម មានជនរងគ្រោះ

---

[34] "គាត់គ្មានសិទ្ធិរស់នៅទេ", សារពត៏មានTime, ថ្ងៃទី៩ ធ្នូ ១៩៩១, D29, ។

[35] Anette Marcher និង យិន សឿម, "ខៀវ សំផន ចង់ទៅ(និយាយ)ជាសាធារណៈ", Phnom Penh Post, ថ្ងៃទី៤-១៧ កុម្ភៈ ២០០០, D29 ។

ម្នាក់បាននិយាយថា៖ "ខ្ញុំចង់ឱ្យពួកគាត់ឈឺចាប់តាមរបៀបដូចដែលខ្ញុំធ្លាប់បានឈឺចាប់ដូច្នោះដែរ" និង"មានតែសម្លាប់ពួកគាត់ប៉ុណ្ណោះទើបធ្វើឱ្យខ្ញុំមានអារម្មណ៍ស្ងប់ស្ងាត់"។ ជនរងគ្រោះនៃរបបខ្មែរក្រហមម្នាក់ផ្សេងទៀត ត្រូវបានគេរាយការណ៍មកថា បាននិយាយថា "គាត់នឹងចិញ្ច្រាំមនុស្សចាស់ម្នាក់នេះ [នួន ជា] ជាចម្រៀកៗហើយរោយអំបិលលើមុខរបួសរបស់គាត់។ គាត់នឹងវាយដំលើរូបគាត់ ធ្វើទារុណកម្មនិងឆក់ខ្សែភ្លើង ដើម្បីឱ្យគាត់និយាយ"[36] ។

ខ. ការគម្រាមកំហែងផ្សេងៗក៏ត្រូវបានធ្វើឡើងផងដែរប្រឆាំងនឹង កាំង ហ្កេកអ៊ាវ *ហៅ* ឌុច នៅក្នុងអម្លុងពេលដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីសំណុំរឿងលេខ០០១ នៅពេលដែលជនរងគ្រោះម្នាក់លាន់មាត់ស្រែកថា ៖ "[]ពួកយើងទាំងអស់គ្នាចង់តែងើបហើយទៅដាល់គាត់" [37] នៅក្នុងពេលដែលសំដែងការខឹងសម្បាររបស់គាត់ចំពោះ ឌុច នោះ មានបងប្រុសរបស់ជនរងគ្រោះម្នាក់ដែលត្រូវបានគេសម្លាប់នៅមន្ទីរស-២១ បាននិយាយនៅក្នុងពេលកំពុងផ្តល់សក្ខីកម្មរបស់គាត់ក្នុងសំណុំរឿងលេខ០០១ថា "[]ជនទាំងឡាយណាដែលមិនឆ្លើយទទួលសារភាពអំពីទោសកំហុស និងមិនព្រមទទួលស្គាល់អំពីការខូចខាតដែលពួកខ្លួនបានបង្ករឡើង គឺមិនបាច់សង្ស័យឡើយ វាជាការដ៏គួរឱ្យស្អប់ខ្ពើម និងគួរឱ្យអស់សំណើចដែលកើនទ្វេរដង"[38]។

គ. នៅក្នុងពេលសន្និសិទសារព័ត៌មានមួយនៅ អវតក កាលពីថ្ងៃទី៤ខែធ្នូ ឆ្នាំ២០០៨ មានមនុស្សបីនាក់បានគម្រាមកំហែងមេធាវីរបស់ជនជាប់ចោទ។ ដោយឃើញច្បាស់ពីភាពទុក្ខសោក មាន

---

[36] Seth Mydans, "នៅក្នុងការកាត់សេចក្តីពួកខ្មែរក្រហម, ពួកជនរងគ្រោះនឹងមិនឈរនៅស្ងៀមជិតនោះទេ", The New York Times, ថ្ងៃទី១៧ មិថុនា ២០០៨, C20/5/7.7 ។

[37] Erika Kinetz និង យុន សាមាន, "ឌុច ប្រឈមមុខនិងចៅក្រមនានា នៅក្នុងសវនាការជាសាធារណៈលើកទី១របស់ អវតក", កាសែត The Cambodia Daily, ចុះថ្ងៃទី២១ វិច្ឆិកា ២០០៧,ឯកសារលេខ C11/11។

[38] ប្រតិចារិក នៃដំណើរការនីតិវិធី, សំណុំរឿងលេខ០០១, ចុះថ្ងៃទី១៧ សីហា ២០០៩, ឯកសារលេខ E1/63.1,ត្រង់ទំព័រ៨៣។

ជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះនានាបានគម្រាមថា "នឹងហៅអេវកម្នាក់ពីពួកអាល់កៃដាមក ហើយស្នើសុំឱ្យគេធ្វើការវាយប្រហារភេរវកម្មមួយនៅ អវតក" បើសិនជាតុលាការមិនដំណើរការជឿនលឿនទៅមុខដើម្បីសម្រេចឱ្យបាននូវភាពយុត្តិធម៌ទេនោះ[39]។

២៦. ដូចដែលអង្គបុរេជំនុំជម្រះ បានសម្រេចរួចហើយនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ថា ប្រតិកម្មនានាខាងផ្លូវអារម្មណ៍ដែលបានបញ្ចេញឱ្យឃើញដោយជនរងគ្រោះនានា គឺជាឧទាហរណ៍អំពីផលប៉ះពាល់នៃជម្ងឺតានតឹងខាងផ្លូវចិត្តក្រោយពីមានការប៉ះទង្គិចយ៉ាងខ្លាំង ("PTSD") ដែលបានលើចឡើងសារជាថ្មីនៅក្នុងចំណោមជនរងគ្រោះនៃរបបខ្មែរក្រហម ដែលជាលទ្ធផលបណ្តាលមកពីដំណើរការនីតិវិធីជំនុំជម្រះក្តីរបស់ អវតក[40]។ កំរិតនៃកំហឹង ហើយនិងអារម្មណ៍នៃការសងសឹកចំពោះជនទាំងឡាយដែលជាអតីតមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម ដែលក្នុងនោះរួមទាំងជនជាប់ចោទផង គឺច្បាស់ណាស់ថា នៅតែខ្ពស់ដដែល[41]។ សហព្រះរាជអាជ្ញា សូមជូនជាសេចក្តីសន្និដ្ឋានថា ភស្តុតាងដូចដែលបានរៀបរាប់ជូនខាងលើនេះ ដែលត្រូវបានពិចារណាតាមការយល់ឃើញអំពីបរិបទនាពេលបច្ចុប្បន្ននេះ គឺជាការបង្ហាញឱ្យឃើញភស្តុតាងយ៉ាងច្បាស់ថា ជនជាប់ចោទ បើសិនជាត្រូវបានធ្វើការដោះលែងនោះមុខជានឹងត្រូវប្រឈមនឹងការប្រថុយគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរចំពោះសន្តិសុខផ្ទាល់របស់គាត់ជាពុំខានឡើយ។

---

[39] អត្ថបទរបស់លោក Claire Duffet, "តុលាការខ្មែរក្រហមប្រល័យពូជសាសន៍ ដួលនៅពេលដែលមេធាវីជនជាតិបារាំងស្នើសុំឱ្យបកប្រែជាថ្មី", Law.com: International News,ចុះថ្ងៃទី១០ ធ្នូ ២០០៨។ សូមអានផងដែរ អត្ថបទរបស់លោក G. Wilkins "ការគ្មានសណ្តាប់ធ្នាប់នៅក្នុងតុលាការនៅពេលដែលសវនាការត្រូវបានបញ្ចប់ក្នុងភាពច្របូកច្របល់"កាសែត The Phnom Penh Post,ថ្ងៃទី៥ ធ្នូ ២០០៨, ឯកសារលេខ C20/5/7.12 ។

[40] អត្ថបទរបស់លោក Rob Savage, "ជម្ងឺតានតឹងខាងផ្លូវចិត្តក្រោយពីមានការប៉ះទង្គិចខ្លាំងៈកេរ្តិ៍ដំណែលមួយនៃការឈឺចាប់ និងអំពើហឹង្សា" ទស្សនាវដ្តី Monthly Southern Globe, ខែតុលា ឆ្នាំ២០០៧, ទំព័រ២៤-២៧, C11/11,ដែលលើកឡើងសំអាងលើសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផនប្រឆាំងនឹងដីកាសម្រេចលើការបន្តចិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣កក្កដា២០០៩, C26/5/26, ត្រង់កថាខណ្ឌទី៥៧។

[41] សូមអាន ការពិភាក្សាស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវឆ្នាំ២០១០ ដោយមជ្ឈមណ្ឌលនៃទីក្រុងប៊ែរឡាំងដើម្បីព្យាបាលជនរងគ្រោះដោយសារទារុណកម្ម ដែលនៅក្នុងផ្នែកបន្ទាប់។

ហេតុដូចនេះ លក្ខខណ្ឌតម្រូវដូចដែលមានចែងនៅក្នុងអនុវិធាន ៦៣.៣.ខ.៤ នៃវិធានផ្ទៃក្នុង គឺត្រូវបានបំពេញគ្រប់គ្រាន់ហើយ។

## *ខ. អំពីហានិភ័យចំពោះសណ្តាប់ធ្នាប់សាធារណៈ*

២៧. ក្នុងការពិចារណាទៅលើលក្ខណៈវិនិច្ឆ័យ ដែលស្រដៀងគ្នានឹងលក្ខណៈវិនិច្ឆ័យដែលត្រូវបានរកឃើញនៅក្នុងអនុវិធាន ៦៣.៣.ខ.៥នៃវិធានផ្ទៃក្នុង តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុបបានសម្រេចថា ដើម្បីបង្ហាញថាការឃុំខ្លួនជាការត្រឹមត្រូវនោះ គឺត្រូវតែបង្ហាញឱ្យឃើញអំពី "អង្គហេតុទាំងឡាយដែលអាចមានលទ្ធភាពបង្ហាញឱ្យឃើញថា ការដោះលែងជនជាប់ចោទប្រាកដជានឹងធ្វើឱ្យរំខានដល់សណ្តាប់ធ្នាប់សាធារណៈ"។ ហើយលើសពីនេះ ត្រូវបង្ហាញឱ្យឃើញថា "ការឃុំខ្លួននឹងនៅតែមានលក្ខណៈស្របច្បាប់ជាបន្តទៅទៀតតែនៅក្នុងករណីដែលសណ្តាប់ធ្នាប់សាធារណៈនៅតែស្ថិតនៅក្រោមការគំរាមកំហែងជាក់ស្តែងជាងដែលប៉ុណ្ណោះ"[42]។ ការប្រើការសាកល្បងពិសោធន៍បែបនេះ ចំពោះករណីរឿងបច្ចុប្បន្ន សហព្រះរាជអាជ្ញាសូមជូនសេចក្តីសន្និដ្ឋានថា គឺមានភស្តុតាងយ៉ាងច្បាស់ថា ការដោះលែងជនជាប់ចោទ មុខជានឹងធ្វើឱ្យមានបញ្ហាអំពីហានិភ័យចំពោះសណ្តាប់ធ្នាប់សាធារណៈចោទឡើងយ៉ាងពិតប្រាកដ។ ការណ៍នេះ ត្រូវបានបង្ហាញជាភស្តុតាងដោយសារចម្លើយនិងប្រតិកម្មផ្សេងៗរបស់ជនរងគ្រោះ, ដោយការសិក្សាស្ទង់មតិជាសាធារណៈ, ដោយអត្រាទូទៅនៃជម្ងឺ PSTD នៅក្នុងប្រទេសកម្ពុជា ហើយនិងដោយសារបរិបទអំពីលក្ខណៈដ៏ផុយស្រួយនៃសង្គមកម្ពុជា៖

[42] *ករណីរឿងក្តីរបស់ Lettelier ទល់នឹង ប្រទេសបារាំង*,តុលាការសិទ្ធិមនុស្សនៃទ្វីបអឺរ៉ុប , ថ្ងៃទី២៦ មិថុនា១៩៩១, កថាខណ្ឌទី៥១។

ក- សភាពការណ៍សន្តិសុខជាទូទៅ នៅក្នុងប្រទេសកម្ពុជាបានចុះទ្រុឌទ្រោម នៅក្នុងរយៈពេលជាងបីឆ្នាំកន្លងទៅនេះ។ ក្នុងឆ្នាំ២០០៩ *របាយការណ៍ស្តីពីសន្ទស្សន៍នៃសន្តិសុខនៅក្នុងពិភពលោក* (*Global Peace Index Report*) ដែលបានធ្វើការពិនិត្យអំពីឧប្បត្តិហេតុនៃអំពើឧក្រិដ្ឋកម្មនានា, ការរំជើបរំជួលជាសាធារណៈ, និងសភាពការណ៍សន្តិសុខទូទៅនៃប្រទេសណាមួយ, បានធ្វើចំណាត់ថ្នាក់ប្រទេសកម្ពុជានៅទី១០៥ ក្នុងចំណោម១៤៤ប្រទេស[43]។ នេះគឺជាតំណាងឲ្យចំណាត់ថ្នាក់ធ្លាក់ចុះរបស់ប្រទេសកម្ពុជា ជាងកាលពីឆ្នាំ២០០៨ ដែលនៅត្រឹមទី៩១[44]។ ក្នុងឆ្នាំ២០១០ ពិន្ទុរបស់ប្រទេសបានចុះទ្រុឌទ្រោមលើសពីមុនទៅទៀត ជាលទ្ធផលគឺស្ថិតនៅក្នុងចំណាត់ថ្នាក់ទី១១១[45]។

ខ- ការសិក្សាស្ទង់មតិ និងការវិភាគមួយក្នុងឆ្នាំ២០១០ អំពីមតិរបស់ជនរងគ្រោះ និងអាកប្បកិរិយារបស់ជនរងគ្រោះនានាចំពោះខ្មែរក្រហម បានរកឃើញថា ជនរងគ្រោះទាំងឡាយនៅតែបន្តរក្សាទុកនូវអារម្មណ៍សងសឹក, មិនអាចអនុគ្រោះទោសឲ្យ, ហើយនិងមានភាពស្ទាក់ស្ទើរនៅក្នុងការផ្សះផ្សារ។ របាយការណ៍ខាងលើនេះបង្ហាញថា អ្នកដែលត្រូវបានគេធ្វើសំភាសន៍ចំនួន៧២,៨% ដែលបានដាក់ពាក្យសុំឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អវតក និងចំនួន៤៩,៩% នៃពួកអ្នកដែលមិនចូលរួមនៅក្នុងដំណើរការនីតិវិធី អវតក បានឆ្លើយថា ពួកគេមានអារម្មណ៍ចង់សងសឹកចំពោះអតីត

---

[43] វិទ្យាស្ថានដើម្បីសេដ្ឋកិច្ច និងសន្តិភាព, សន្ទស្សន៍អំពីសន្តិភាពសាកលលោក, *វិធីសាស្ត្រ លទ្ធផល និង ការរកឃើញ ឆ្នាំ២០០៩,* C22/9/10.1, ទំព័រ១១១។

[44] វិទ្យាស្ថានដើម្បីសេដ្ឋកិច្ច និងសន្តិភាព, សន្ទស្សន៍អំពីសន្តិភាពសាកលលោក, *វិធីសាស្ត្រ លទ្ធផល និង ការរកឃើញ ឆ្នាំ២០០៨* ។ សូមអានសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបដិសេធលើសំណើសុំដោះលែង និងដីកាសំរេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី៣ កក្កដា ២០០៩, C26/5/26, ត្រង់កថាខណ្ឌទី៦២។

[45] វិទ្យាស្ថានដើម្បីសេដ្ឋកិច្ច និងសន្តិភាព, សន្ទស្សន៍អំពីសន្តិភាពសាកលលោក, *វិធីសាស្ត្រ លទ្ធផល និង ការរកឃើញ ឆ្នាំ២០១០,* [អំពីភស្តុតាងថ្មីៗដែលជូនភ្ជាប់ជាឧបសម្ពន្ធទី១]។ របាយការណ៍នេះ និយាយនៅត្រង់ទំព័រ១៤ ៖ “ដោយកាលពីឆ្នាំទៅ មានការកត់សំគាល់ពីការបែងចែកនៅក្នុងទ្វីបអាស៊ីភាគអាគ្នេយ៍ ដោយមាន ប្រទេសតៃវ៉ាន់ វៀតណាម និងឥណ្ឌូណេស៊ី ដែលតាំងអស់សុទ្ធតែស្ថិតនៅក្នុងចំណោម៧០ប្រទេសលើគេបង្អស់។ ចំណែកឯប្រទេសកម្ពុជា ប្រទេសថៃឡង់ និងហ្វីលីពីនដែលទាំងអស់នេះសុទ្ធតែស្ថិតនៅក្នុងចំណាត់ថ្នាក់ទាបក្រោមពីទី១១០។ ពិន្ទុនៅក្នុងប្រទេសទាំងបីនេះបានថយចុះទៀតពីឆ្នាំមុន ដោយសារតែមានការកើនឡើងនៃអស្ថេរភាពនយោបាយដែលជាប្រធានបទរួម ” ។

ខ្មែរក្រហម។ នៅពេលសួរសំនួរថាតើពួក គេអនុគ្រោះទោសឱ្យអតីតពួកខ្មែរក្រហមដែរឬទេ? មានអ្នកដែលត្រូវបានគេធ្វើសំភាសន៍ចំនួន ៧៦,១% ក្នុងប្រភេទទី១ និង ៥៨,៥%នៃប្រភេទទី២ បានឆ្លើយជាអវិជ្ជមាន។ រីឯការសួរថាតើពួកគេមានត្រៀមលក្ខណៈដើម្បីធ្វើការផ្សះផ្សាដែរឬទេ? មាន ៦៦,៨% នៃអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង៥៩,៤% នៃអ្នកមិនចូលរួមនៅក្នុងដំណើរការនីតិវិធី អវតក បានឆ្លើយជាអវិជ្ជមាន។ អ្នកចូលរួមដែលមានចំនួនលើសពីពីរភាគបីបាននិយាយថាការផ្សះផ្សាជាមួយពួកខ្មែរក្រហមមិនទាន់បានកើតឡើងនៅឡើយទេនៅក្នុងភូមិរបស់ពួកគាត់[46]។

គ- នៅក្នុងពេលកំពុងធ្វើសវនាការជំនុំជម្រះក្តីលើករណីលេខ០០១ លោកវេជ្ជបណ្ឌិត ឈឹម សុធារ៉ា អ្នកជំនាញផ្នែកចិត្តវិទ្យា បានពិភាក្សាអំពីផលប៉ះពាល់នៃជម្ងឺ PTSD និងបានផ្តល់មតិថា មានជនរងគ្រោះដោយជម្ងឺប៉ះទង្គិចខាងផ្លូវចិត្តចំនួនច្រើនរាប់មិនអស់ដែលងាយនឹងទទួលបាននូវការធ្លាប់បាក់ទឹកចិត្ត, ឆាប់ខឹង, ចូលចិត្តផឹកសុរា, និងអំពើហឹង្សានៅក្នុងគ្រួសារ[47]។ លោកបានសង្កត់ធ្ងន់ថា ការបដិសេធមិនព្រមទទួលខុសត្រូវរបស់ជនទាំងឡាយដែលត្រូវបានគេយល់ថា ជាអតីតមេដឹកនាំខ្មែរក្រហមនោះគឺជាការរាំងខ្ទប់មិនឱ្យមានការជាសះស្បើយខាងផ្លូវចិត្តរបស់ជនរងគ្រោះកម្ពុជានានា ហើយថែមទាំងបង្កើតបានជាបន្ទុកបន្ថែមដ៏ធំមួយដល់ពួកគេទៀតផង[48]។

---

[46] មជ្ឈមណ្ឌលនៃទីក្រុងប៊ែរឡាំងដើម្បីព្យាបាលជនរងគ្រោះដោយសារទារុណកម្ម , សម្លេងរបស់"អ្នកដែលរួចរស់ជីវិតៈ ឥរិយាបថចំពោះ អវតក,អតីតខ្មែរក្រហម និងបទពិសោធន៍អំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ," ខែធ្នូ ឆ្នាំ២០១០, ត្រង់ទំព័រ៣១-៣៣ [Annex 2ភ្ជាប់]។

[47] ប្រតិចារឹកនៃដំណើការនីតិវិធីនៃការជំនុំជម្រះក្តី, សំណុំរឿងលេខ០០១, ចុះថ្ងៃទី២៥ ខែសីហា ២០០៩, E1/68.1, ទំព័រ១៥-១៦។

[48] ដូចគ្នានឹងខាងលើ, ទំព័រ៣៨។

ឃ. អ្នកជំនាញផ្សេងៗទៀតបានធ្វើសេចក្តីអធិប្បាយផ្តល់មតិថា នៅពេលដែលឧប្បត្តិហេតុនានានៃជម្ងឺខាងផ្លូវចិត្តចេះតែលេចឡើងពីមួយឆ្នាំទៅមួយឆ្នាំ ការព្យាបាលជម្ងឺផ្លូវចិត្តដល់ជនរងគ្រោះនៅតែមិនគ្រប់គ្រាន់ដដែល[49]។

២៨. ដោយសារតែដំណាក់កាលនៃដំណើរការនីតិវិធីលើសំណុំរឿងលេខ០០២ វិសាលភាពនៃការចោទប្រកាន់ដែលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងផលប្រយោជន៍សាធារណៈដ៏ធំសម្បើមនៅក្នុងករណីរឿងនេះ ការដោះលែងជនជាប់ចោទមុខជាធ្វើឱ្យស្ថានភាពរបស់ជនរងគ្រោះនានានៅទូទាំងប្រទេសកាន់តែមានសភាពធ្ងន់ធ្ងរឡើងថែមទៀតយ៉ាងពិតប្រាកដ ហើយជាផលវិបាកគឺការផ្តល់នូវហានិភ័យដ៏ធំចំពោះសណ្តាប់ធ្នាប់សាធារណៈ។ ការឃុំខ្លួនបណ្តោះអាសន្នគឺនៅតែជាវិធានការណ៍ដ៏ចាំបាច់សម្រាប់ធានានាដល់សណ្តាប់ធ្នាប់សាធារណៈជាដដែល ហើយហេតុនេះ លក្ខខណ្ឌតម្រូវនៅក្នុងអនុវិធាន ៦៣.៣.ខ.៥នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញគ្រប់សព្វហើយ។

## VII. អង្គជំនុំជម្រះសាលាដំបូងមិនបានរំលោភលើក្នុងការសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តធម៌របស់ជនជាប់ចោទឡើយ

២៩. ដោយសារតែ ជនជាប់ចោទធ្វើពាក្យសុំឱ្យដោះលែងដោយមិនបានផ្អែកលើមូលដ្ឋាននៃកាលៈទេសៈដែលមានការប្រែប្រួលនោះ ការលើកឡើងតវ៉ារបស់គាត់ដែលថា អង្គជំនុំជម្រះសាលាដំបូងបានរំលោភលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ដោយខកខានមិនបានផ្តល់ឱ្យគាត់នូវនូវពេល

[49] ការដើរថយក្រោយដ៏វែងឆ្ងាយរបស់ប្រទេសកម្ពុជា។ វេជ្ជបណ្ឌិតនានាខំប្រយុទ្ធតស៊ូដើម្បីព្យាបាលជម្ងឺរបស់ប្រទេសដែលមានបញ្ហា, កាសែត AFP, ថ្ងៃទី៣ កញ្ញា ២០០៧។

វេលាគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្តីគឺមិនមានមូលដ្ឋានឡើយ។ ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទីV ខាងលើរួចហើយ គឺអង្គជំនុំជម្រះសាលាដំបូងមិនគ្រាន់តែបានផ្តល់ដល់ជនជាប់ចោទនូវជម្រើសមួយដើម្បីដាក់សារណាផ្អែកតាមអនុវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ, តែថែមទាំងបានជំរាបគាត់ឲ្យបានដឹងថាគាត់មានសិទ្ធិអាចដាក់ពាក្យសុំដោះលែងថ្មីមួយទៀតបានទៀតផង។

៣០. ជនជាប់ចោទបានតវ៉ាថា លើសពីនេះ អង្គជំនុំជម្រះសាលាដំបូង ថែមទាំងបានរំលោភលើសិទ្ធិក្នុងការទទួលបាន នូវការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ដោយខកខានមិនបានពិចារណាពីលទ្ធភាពក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការនិងមិនអើពើចំពោះសារណារបស់គាត់លើចំណុចនេះ។ ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកទីIV ខាងលើថា ដោយសារតែសារណារបស់ជនជាប់ចោទដែលឲ្យអនុវត្តតាមអនុវិធាន៦៨.៣ ត្រូវបានបដិសេធចោលនោះ ការឃុំខ្លួនរបស់គាត់បានបន្តទៅទៀតតាមអានុភាពនៃអនុវិធាន៨២.១នៃវិធានផ្ទៃក្នុង។ គឺគ្រាន់តែនៅពេលក្រោយពីមានពាក្យសុំឲ្យដោះលែងមួយដែលមានបញ្ជាក់មូលហេតុត្រឹមត្រូវតាមអនុវិធាន៨២.២ ដែលគាំទ្រដោយភស្តុតាងដូចជាអំពីការឃុំខ្លួនណាមួយដែលជាជំនួស ដែលអាចរំពឹងទុកថា អង្គជំនុំជម្រះនឹងពិចារណាចំពោះការជំនួសដ៏ជាក់លាក់ណាមួយឲ្យការឃុំខ្លួននោះ។ សារណាដែលមានលក្ខណៈទូទៅ និងខ្លីដែលធ្វើឡើងដោយមេធាវីការពារជនជាប់ចោទនៅក្នុងសវនាការមិនបានជំរុញអំពីកាតព្វកិច្ចនេះឡើយ។ សារណាដែលស្រដៀងគ្នានេះ ដែលធ្វើឡើងដោយមេធាវីដដែល កាលពីលើកមុនត្រូវបានអង្គបុរេជំនុំជម្រះ បដិសេធចោលព្រោះដោយមិនមានការគាំទ្រដោយភស្តុតាងណាមួយសោះ[50]។

[50] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តថិរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី៣០ មេសា ២០១០, C26/9/12, ត្រង់កថាខណ្ឌទី៣៤។

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

៣១. ជាចុងក្រោយ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា នៅក្នុងករណីណាក៏ដោយ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការមិនមែនជាវិធានការដ៏សមស្របដើម្បីថែរក្សាការពារប្រឆាំងនឹងហានិភ័យចំពោះសុវត្ថិភាពផ្ទាល់របស់ជនជាប់ចោទ និងសណ្តាប់ធ្នាប់សាធារណៈនោះឡើយ ដូចដែលបានពិភាក្សាពីខាងលើរួចហើយ។

## VIII. សេចក្តីសន្និដ្ឋាន

៣២. ដោយមូលហេតុដូចដែលបានរៀបរាប់ខាងលើនេះ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានខកខានមិនបានបង្ហាញភស្តុតាងឱ្យឃើញពី អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនូវកំហុសឆ្គងមួយដែលអាចឱ្យយល់បាន នៅក្នុងការអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនដែលបណ្តាលឱ្យមានការខូចខាតដល់សិទ្ធិ/ផលប្រយោជន៍របស់គាត់នោះឡើយ។ សហព្រះរាជអាជ្ញា សូមគោរពស្នើដល់អង្គជំនុំជម្រះតុលាការកំពូល សុំឱ្យ៖

ក. ច្រានចោលនូវសំណើរបស់ជនជាប់ចោទដែលសុំឱ្យកែប្រែនូវសេចក្តីសម្រេចដែលមានការតវ៉ាជំទាស់នេះ និងដែលសុំឱ្យដោះលែងរូបគាត់ជាបន្ទាន់ និងសុំឱ្យធ្វើការបញ្ជាក់ថា គាត់ត្រូវបានឃុំខ្លួនដោយត្រឹមត្រូវអនុលោមតាមអនុវិធាន៨២.១ នៃវិធានផ្ទៃក្នុង។ និងសុំឱ្យ

ខ. ដាក់ជំនួសមូលហេតុទាំងឡាយដូចដែលមានចែងនៅក្នុងផ្នែកទីVIខាងលើ ដោយមូលហេតុដូចដែលបានផ្តល់ជូនដោយអង្គជំនុំជម្រះសាលាដំបូង ដូចមាននៅក្នុងកថាខណ្ឌទី៤០នៃសេចក្តី

០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

សម្រេចដែលមានការតវ៉ាជំទាស់វិញ ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថាចាំបាច់ត្រូវធ្វើការពិចារណាឡើងវិញលើហេតុផលជាសារវន្តក្នុងការឃុំខ្លួន៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ | **លោក យ៉េត ចរិយា** សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** William Smith សហព្រះរាជអាជ្ញារង | | |